ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣៨៧

ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១

**សាលដីកា**

លេខ ៣៨២ “III”

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

ដែលមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម ៖

១-លោកជំទាវ [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-លោកជំទាវ [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៣៣៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] WORAPHA និងបណ្តឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] RUTHAIRAT ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៤ “ក្រVI.គ.ធ” ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

- **ជនជាប់ចោទ៖**

១-ឈ្មោះ [redacted] WORAPHA ([redacted] វ៉រ៉ាផា) ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ សាសនាព្រះពុទ្ធ មុខរបរធ្វើចំការ មានទីកន្លែងកំណើតនៅឃុំយ៉ាងថូន ស្រុកណុងម្លូង ខេត្តលុបបូរី ប្រទេសថៃ ទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ស្រុកណុងម្លូង ខេត្តលុបបូរី ប្រទេសថៃ ឪពុកឈ្មោះ [redacted] TONGOON (ស) ម្តាយ ឈ្មោះ [redacted] TONGOON (រ) ប្តីឈ្មោះ [redacted] មានកូនចំនួន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៥២១ "ជ១"ង.ឃ.ង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ នៅមណ្ឌលអប់រំកែប្រែទី២ (មង២) ។

២-ឈ្មោះ [redacted] RUTHAIRAT (សូស៊ីន រ៉ូថៃរ៉ាត់) ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ សាសនាព្រះពុទ្ធ មុខរបរកម្មករ មានទីកន្លែងកំណើតនៅឃុំយ៉ាងថូន ស្រុកណាងមួន ខេត្តលុបបូរី ប្រទេសថៃ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះ [redacted] ប្រទេសថៃ ឪពុកឈ្មោះ [redacted] (រ) ម្តាយ ឈ្មោះ [redacted] ស) ប្តីឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៥២០ "ជ១"ង.ឃ.ង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ នៅមណ្ឌលអប់រំកែប្រែទី២ (មង២) ។

៣-ឈ្មោះ [redacted] KANOKNUD ហៅ ក្វាង ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិថៃ ទីលំនៅបច្ចុប្បន្នស្នាក់នៅ No307 Soi On-nuch Sub-District ទីក្រុង Bangkok ប្រទេសថៃ កាន់អត្តសញ្ញាណបណ្ណលេខ 3480500578193 កាន់លិខិតឆ្លងដែនលេខ AA8158339 ជានីតិជន ទោសពីមុនគ្មាន ។

**ជាប់ចោទពីបទ** រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ពីប្រទេសកម្ពុជាទៅកាន់ទីក្រុងតូក្យូប្រទេសជប៉ុន) ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ២៣ និង៥០នាទី មន្ត្រីនគរបាលនៃមន្ទីរប្រឆាំងគ្រឿងញៀន និងដោយសហការជាមួយសមត្ថកិច្ចគយ និងរដ្ឋាករនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានធ្វើការឃាត់ខ្លួនជនត្រូវចោទជាអ្នកដំណើរចំនួន០២នាក់ មានឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ កាន់លិខិតឆ្លងដែនលេខ AA ៨៥៧៩៨៩៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ និងឈ្មោះ S [redacted] RUTHAIRAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ កាន់លិខិតឆ្លងដែនលេខ AA៨៧៣៩៩០៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ នៅចំណុចស្ថានីយ៍អ្នកចេញដំណើរពីប្រទេសកម្ពុជាទៅកាន់ទីក្រុងតូក្យូ ប្រទេសជប៉ុន តាមជើងហោះហើរលេខ NH៨១៨ និងបានឆែកឆេរក្នុងអាវរងាររបស់ជនត្រូវចោទទាំង០២នាក់ រកឃើញមានម្សៅក្រាមពណ៌ស ប្រភេទមេតំហ្វេតាមីន ដែលលាក់បង្កប់ក្នុងអាវរងាររបស់ជនត្រូវចោទឈ្មោះ [redacted] RUTHAIRAT មានទម្ងន់សរុប ២,៧៥៦,៤៤ក្រាម និងរបស់ជនត្រូវចោទឈ្មោះ [redacted] WORAPHA មានទម្ងន់សរុប ១,៧៥០,៧៦ក្រាម។ ចំណែកឈ្មោះ ក្វាង ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ជនជាតិថៃ ប្រើប្រាស់ទូរស័ព្ទលេខ ០៦៩ ៦៣០ ៣៦២ និង [redacted] ដែលជាម្ចាស់គ្រឿងញៀន និងជាមេក្លោងជាអ្នករៀបចំចាត់ចែង និងប្រគល់សារធាតុញៀនឱ្យជនត្រូវចោទទាំង០២នាក់ នេះនៅខេត្តសៀមរាប បានគេចខ្លួនបាត់ ។



Scanned with CamScanner

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទ៖

១.១-ឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ (សាមសិប)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០លានរៀល(ហុកសិបលានរៀល)។

១.២-ឈ្មោះ [redacted] RUTHAIRAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល៣០ (សាមសិប)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០លានរៀល (ហុកសិបលានរៀល)។

១.៣-ឈ្មោះ [redacted] KANOKNUD ហៅ ក្វាង ភេទស្រី អាយុប្រហែល ៣៦ឆ្នាំ ជនជាតិថៃ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ (សាមសិប)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០លានរៀល (ប៉ែតសិបលានរៀល)។

ពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] KANOKNUD ហៅ ក្វាង ភេទស្រី អាយុ ៣៦ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-វត្ថុចាប់យកមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកពីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញលេខ ៧៧០ប.វ.ត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ មាន ១.ម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ២,៧៥៦.៤៤ (ពីរពាន់ប្រាំពីររយហាសិបក្រាម និងសែសិបបួន) និង២. ក្រាមពណ៌សថ្លា ទម្ងន់សរុប ១,៧៥០.៧៦ (មួយពាន់ប្រាំពីររយហាសិបក្រាម និងចិតសិបប្រាំមួយ) សម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ៣. ទូរស័ព្ទម៉ាក Oppo ពណ៌ស-ផ្កាឈូក មិនដំណើរការ ០១គ្រឿង និងម៉ាក HUAWEI ពណ៌ទឹកមាស មិនដំណើរការ ០១គ្រឿង និងអត្តសញ្ញាណប័ណ្ណជនជាតិថៃ ចំនួន០១សន្លឹក,លិខិតឆ្លងដែនចំនួន០២ក្បាល និងសំបុត្រយន្តហោះចំនួន០១សន្លឹក សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] WORAPHA, ឈ្មោ[redacted] RUTHAIRAT និងកំបាំងមុខជនត្រូវចោទឈ្មោះ [redacted] KANOKNUD ហៅ ក្វាង និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] WORAPHA, ឈ្មោ[redacted] RUTHAIRAT និងកំបាំងមុខជនត្រូវចោទឈ្មោះ [redacted] KANOKNUD ហៅ ក្វាង ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១៧៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ របស់លោក [redacted] ហ្វូឡាយ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WORAPHA និងឈ្មោះ [redacted] UTHAIRAT ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៥៤ "ក្រVI.គ.ធ" ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ១៧៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ របស់លោក[redacted]ហ្វូឡាយ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WORAPHA [redacted]វ៉ូរ៉ាផា) និងឈ្មោះ [redacted] RUTHAIRAT (សូស៊ីន រ៉ូថៃរ៉ាត់) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] WORAPHA ([redacted]វ៉ូរ៉ាផា) និងឈ្មោះ [redacted] RUTHAIRAT ([redacted]រ៉ូថៃរ៉ាត់) តាមនីតិវិធី ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ, ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៣៣៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] WORAPHA ប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌ ៥៤ "ក្រVI.គ.ធ" ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] RUTHAIRAT ប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌ ៥៤ "ក្រVI.គ.ធ" ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

## នាពេលសវនាការនៅតុលាការកំពូល

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្ដីសន្និដ្ឋាននិងប្ដឹងសុំថា ជនជាប់ចោទពុំបានដាក់សារណាការពារ បណ្ដឹងសាទុក្ខជូនតុលាការកំពូល ដូច្នេះតុលាការកំពូលពុំមានមូលហេតុពិចារណាតាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តំណាងមហាអយ្យការសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ ។

-មេធា[redacted] ប៊ូរ៉ា ការពារឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ដោយសារតែខ្លួនបានដាក់សារណាការពារមកតុលាការកំពូលហើយ ។ ខ្លួនយល់ឃើញថាសេចក្ដីសម្រេចរបស់តុលាការអង្គហេតុមានកំហុសឆ្គងផ្នែកច្បាប់ ។ តាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះសំអាងហេតុនៃការដាក់ពន្ធនាគារ គឺពុំមានធាតុផ្សំគ្រប់គ្រាន់ទេ ដែលតុលាការកំពូលអាចពិចារណាលើបណ្ដឹងសាទុក្ខរបស់កូនក្ដីខ្លួនបាន ។ នៅ



Scanned with CamScanner

ក្នុងអង្គហេតុនេះ ការរឹបអូសគ្រឿងញៀនបានជិត៥ គីឡូ ដោយរឹបអូសពីឈ្មោះ [redacted] RUTHAIRAT ចំនួន ៣គីឡូ នឹងរឹបអូសពីឈ្មោះ [redacted] WORAPHA ចំនួន ២ គីឡូ ដែលសរុបធាតុសុទ្ធមានចំនួនជិត ៥០% ចំពោះការផ្តន្ទាទោសអាចពី ៣០ ឆ្នាំ ទៅ ១ជីវិត ។ ប៉ុន្តែសាលាដំបូងបានសម្រេចផ្តន្ទាទោសចំនួន ៣០ ឆ្នាំ ហើយសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញផងដែរ ។ ចំពោះគោលការណ៍ឯកត្តកម្មនៃទោស និងគោលការណ៍សមាមាត្រានៃការដាក់ទោស គឺអ្នកដែលប្រព្រឹត្តត្រូវទទួលទោស ប្រសិនបើយកគ្រឿងញៀនដែលរឹបអូសបានមកញែក រកធាតុសុទ្ធ នោះអាចមានការប្រែប្រួល ដូច្នេះការដាក់ពន្ធនាគារលើកូនក្តីខ្លួនចំនួន ៣០ ឆ្នាំ ដូចគ្នា គឺសំអាងហេតុពុំច្បាស់លាស់ ។

**សំណូមពរ** សូមប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ និងបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

**១-យល់ឃើញថា** បណ្តឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] វ៉ូរ៉ាផា [redacted] WORAPHA) និងបណ្តឹងសាទុក្ខលេខ ៣៣៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] រ៉ូថៃរ៉ាត់ ([redacted] RUTHAIRAT) ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាច លើយករឿងនេះមកជំនុំជម្រះបានតាមមាត្រាបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**២-យល់ឃើញថា** ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមរបស់សាលាដំបូងដែលបានកំណត់ពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទទាំងពីររូបឈ្មោះ [redacted] វ៉ូរ៉ាផា ([redacted] WORAPHA) និងជនជាប់ចោទឈ្មោះ [redacted] រ៉ូថៃរ៉ាត់ [redacted] RUTHAIRAT) ពីបទរក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចស្ថានីយ៍ចេញដំណើរនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះ ជាមិនត្រឹមត្រូវទេ ព្រោះថា៖

-តុលាការអង្គហេតុ មិនបានកំណត់អំពីប្រភេទគតិយុត្តនៃបទល្មើសឱ្យបានត្រឹមត្រូវ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២នៅឡើយ ។ តាមមាត្រា ៤០ កថាខណ្ឌទី១, ២ និង ៣ នេះ បានកំណត់អំពីធាតុផ្សំនៃអំពើក្នុងបទល្មើសរក្សាទុក, បទដឹកជញ្ជូន និងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ករណីនេះ តាមភស្តុតាងដាក់បន្ទុកអាចកំណត់បានត្រឹមតែអំពើក្នុងបទល្មើសរក្សាទុក និងបទដឹងជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀនប៉ុណ្ណោះ ។



Scanned with CamScanner

-តាមកំណត់ហេតុនៃការឃាត់ខ្លួន និងកំណត់ទទួលស្គាល់សម្ភារៈវត្ថុតាងនៅនគរបាលយុត្តិធម៌ ឃើញថា វត្ថុតាងគ្រឿងញៀនដែលដកហូតសរុប ៤៥០៧,២ ក្រាម ប៉ុន្តែវត្ថុតាងគ្រឿងញៀន ចំនួន ១៧៥០,៧៦ ក្រាម ត្រូវបានដកហូត ចេញពីការកាន់កាប់របស់ជនជាប់ចោទឈ្មោះ [redacted]វ៉ូរ៉ាផា ([redacted] WORAPHA) និងវត្ថុតាង គ្រឿងញៀនចំនួន ២៧៥៦,៤៤ ក្រាម ត្រូវបានដកហូត ចេញពីការកាន់កាប់របស់ជនជាប់ចោទ ឈ្មោះជនជាប់ចោទឈ្មោះ [redacted] រ៉ូថៃរ៉ាត់ ([redacted] RUTHAIRAT) ។ ករណីនេះ ក្នុងសំអាងហេតុរបស់តុលាការអង្គហេតុកន្លងមកបានពិចារណារួមតែម្តង ដែលជាការអនុវត្តច្បាប់មិនបានត្រឹមត្រូវតាមមាត្រា ២៤ (គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវ) នៃក្រមព្រហ្មទណ្ឌ ។

ដូច្នេះ តាមសំអាងហេតុខាងលើនេះ បុគ្គលប្តឹងសាទុក្ខ មានមូលហេតុនៃការប្តឹងសាទុក្ខស្របតាម មាត្រា ៤១៩ (មូលហេតុនៃបណ្តឹងសាទុក្ខ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**៣-យល់ឃើញថា** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាននាសវនាការនេះថា សេចក្តីសម្រេចរបស់តុលាការអង្គហេតុមានកំហុសឆ្គងផ្នែកអង្គច្បាប់ ជាអាទិ៍សហជនជាប់ចោទទាំងពីរជាបុគ្គលប្តឹងសាទុក្ខ គ្រាន់តែជាចារីធម្មតា តែត្រូវបានប្រកាសទោសក្នុងកម្រិតស្មើគ្នានឹង ជនជាប់ចោទ ជាមេក្លោងឈ្មោះ ប៊ុនថាំង កាណុងនុត ហៅ ក្វាង [redacted] KANOKNUD) ដែលរត់គេចខ្លួន, ទោសត្រូវបានប្រកាស តាមបរិមាណធាតុសុទ្ធនៃសារធាតុញៀនសរុបដែលបានរឹបអូស ដោយមិនបានពិចារណាដែលការណ៍នេះ ជាការអនុវត្តមិនបានពិចារណាអំពីគោលការណ៍ឯកត្តកម្មនៃទោស និងគោលការណ៍សមាមាត្រនៃការដាក់ទោស ។ ខ្លួនស្នើសុំឱ្យតុលាការកំពូលសម្រេចបដិសេធ និងបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញ ។ សេចក្តីសន្និដ្ឋាននេះ មានលក្ខណៈត្រឹមត្រូវ ដែលតុលាការកំពូលពិចារណាដូចសំអាងហេតុខាងលើនេះ ។

**៤-យល់ឃើញថា** តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលនៅក្នុងកិច្ចពិភាក្សាដេញដោលនាពេលសវនាការ បានលើកឡើងថា ការប្តឹងសាទុក្ខរបស់ជនជាប់ចោទពុំបានដាក់សារណាការពារបណ្តឹងសាទុក្ខ ជូនមកតុលាការកំពូលតាមនីតិវិធីហើយ សាលដីកាព្រហ្មទណ្ឌលេខ ៥៤ “ក្រVI.គ.ធ” ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ហើយ ហេតុនេះ ស្នើសុំក្រុមប្រឹក្សាពិចារណានិងសម្រេច ។ ករណីនេះ តុលាការកំពូលបានពិចារណាដូចមានខាងលើនេះ។

**៥-យល់ឃើញថា** សាលដីកាព្រហ្មទណ្ឌលេខ ៥៤ “ក្រVI.គ.ធ” ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ខុសនឹងគតិច្បាប់ ។

## ហេតុដូច្នេះ

## សម្រេច

**១-ទទួល** បណ្តឹងសាទុក្ខលេខ ៣៣៥ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] WORAPHA) និងបណ្តឹងសាទុក្ខលេខ ៣៣៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted]ថៃរ៉ាត់ [redacted]UTHAIRAT) ។

**២-បដិសេធ** សាលដីកាព្រហ្មទណ្ឌលេខ ៥៤ “ក្រVI.គ.ធ” ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។



Scanned with CamScanner

**៣-បញ្ជូន**សំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ។

**៤-បន្ត**រក្សាការឃុំខ្លួនបណ្ដោះអាសន្នលើជនជាប់ចោទឈ្មោះ [redacted] ([redacted]WORAPHA) និងជនជាប់ចោទឈ្មោះ [redacted] ([redacted] RUTHAIRAT) តាមនីតិវិធី ។

សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| លោកជំទាវ | [redacted] | ជាប្រធាន |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

**បានចម្លងត្រឹមត្រូវតាមសាលដីកាដើម។**

ថ្ងៃព្រហស្បតិ៍ ៦ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ថ្ងៃព្រហស្បតិ៍ ៦ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner